**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រៃវែង**
លេខ..៤៤១/សរ.ដណ/២០

ថ្ងៃ ពុធ ១៣កើត ខែ ភទ្របទ ឆ្នាំ ជូតទោស័ក ព.ស ២៥៦៤
ព្រៃវែង, ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
# ស្តីពី
# ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០២១

យោង: សេចក្តីជូនដំណឹងលេខ ០០១ ស.ណ.ន/គ.ជ.អ.ប ចុះថ្ងៃទី ០៧ កញ្ញា ឆ្នាំ ២០២០ ស្តីពី សេចក្តីណែនាំក្នុងការរៀបចំបញ្ជីឈ្មោះ អ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ ២០២១ ។

អភិបាលនៃគណៈអភិបាល ខេត្តព្រៃវែង នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០២១សម្រាប់ដេញថ្លៃ គម្រោង មូលនិធិ ឃុំសង្កាត់ ឆ្នាំ២០២១។អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់ សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ០៣ ប្រភេទ ៖

- ប្រភេទទី១ ៖ អ្នកទទួលការសំណង់ទូទៅ ( ការងារសំណង់អគារ និងការងារបេតុង ...។ ល។ )
- ប្រភេទទី២ ៖ អ្នកទទួលការការងារដី ( ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ...។ល។ )
- ប្រភេទទី៣ ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ គណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំង ក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការ ជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ គណៈកម្មការបុរេលក្ខណសម្បត្តិ នឹងដាក់ជូន អភិបាលខេត្ត ដើម្បីពិនិត្យនិងសម្រេច ។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរក ឃើញ ថាមានការពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ និងអំពីពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណា ក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុង បញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការ និងវិនិយោគ សាលាខេត្តព្រៃវែង ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ **ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៧.០០នាទី** ល្ងាច។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ពាក្យ សុំចុះឈ្មោះ ក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគដោយឥតបង់ថ្លៃ តាមអាសយដ្ឋានស្ថិតក្នុងបរិវេណសាលាខេត្តព្រៃវែង ឬអាចទាញយកពី ក្នុងគេហទំព័ររបស់ គ.ជ.អ.ប។

ត.ប **អភិបាលខេត្ត**
**នាយករដ្ឋបាល**

ឈាង សុវណ្ណារ៉ា

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ក្រុមប្រឹក្សាខេត្ត ដើម្បីជូនជ្រាប
-ឯកសារកាលប្បវត្តិ

ភូមិលេខ១ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
1Village,Sangkat Kampong Leav,Krong Prey Veng,Prey Veng Province
ទូរស័ព្ទ និងទូរសារ: (+៨៥៥) ៤៣ ២១៨ ៨៨៨,អ៊ីម៉ែល: preyvengprovince@gmail.com.kh
Phone and Fax: (+855) 43 218 888, Email: preyvengprovince@gmail.com.kh